# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## សេចក្តីប្រកាសព័ត៌មាន

### កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016
### (សេដ្ឋកិច្ច ក្រុមទី៨៖ ប្រព័ន្ធដឹកជញ្ជូន)

លេខ: 03 PR-17/EoJ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧

តាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន១៥រូប នឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី១៧ ដល់ថ្ងៃទី២៥ ខែមេសា ជាមួយក្រុមយុវជនមកពីបណ្តាប្រទេសអាស៊ាន ទីម័រខាងកើត និងប្រទេសឥណ្ឌា ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិត និងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត ដែលហៅកាត់ថា JENESYS 2016។

ក្រុមយុវជននឹងចូលរួមស្តាប់បទបង្ហាញទាក់ទងនឹងប្រព័ន្ធដឹកជញ្ជូនរបស់ប្រទេសជប៉ុន ដោយក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍របស់ប្រទេសជប៉ុន។ បន្ទាប់មក ក្រុមយុវជននឹងបន្តធ្វើទស្សនកិច្ចទៅកាន់ខេត្តមីយ៉ាគី តាមស៊ីនកាន់សេនដែលជារថភ្លើងល្បឿនលឿនបំផុត ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរជាមួយស្ថាប័ននានា និងបណ្តាក្រុមហ៊ុនឯកជនក្រោមប្រធានបទ"**ប្រព័ន្ធដឹកជញ្ជូន**"។ ក្រុមយុវជនក៏នឹងមានឱកាសទទួលបទពិសោធន៍អំពីការស្តារឡើងវិញនូវខ្សែរថភ្លើងដែលត្រូវរងការបំផ្លិចបំផ្លាញដោយមហាគ្រោះរញ្ជួយដីភាគខាងកើតជប៉ុនផងដែរ។ កម្មវិធីលម្អិតមានភ្ជាប់ជាមួយសេចក្តីប្រកាសព័ត៌មាននេះ។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងការកសាងទំនុកចិត្តទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះ ក្រសួងការបរទេសជប៉ុនបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២០០០នាក់ហើយ តាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួម នឹងអាចយល់ដឹងអំពីប្រទេសជប៉ុនកាន់តែស៊ីជំរៅថែមទៀត ព្រមទាំងចែករំលែកនូវបទពិសោធរបស់ពួកគេទៅកាន់ប្រជាជនកម្ពុជា បន្ទាប់ពីពួកគេវិលត្រលប់មកវិញ។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Fax: 023 216 162*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*